# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០៩៨ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០១៦

## ប្រកាស

## ស្តីពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.**_

ប្រកាសនេះ មានគោលបំណងកំណត់ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ដែលបាននឹងកំពុងប្រកបវិជ្ជាជីវៈអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ឧទ្ទេសឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

**ប្រការ ២._**

ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិត្រូវកំណត់ដូចខាងក្រោម ៖

- អាវសឺមីដៃវែង និងដៃខ្លី មានផ្ទៃពណ៌លឿងមាស មានហោប៉ៅពីរមានគំរប។
- ផ្នែកខាងឆ្វេងនៃអាវ ត្រូវពាក់ស្លាកឈ្មោះ មានផ្ទៃពណ៌ទឹកប៊ិចចាស់ ដែលមានប្រវែង ១២ សម កំពស់ ៣ សម និងត្រូវបញ្ជាក់អំពីឈ្មោះ និងអត្តលេខរបស់មគ្គុទ្ទេសក៍ខ្លួនផ្ទាល់។ នៅលើដៃផ្នែកខាងឆ្វេងត្រូវមានស្លាកសញ្ញារបស់ក្រសួងទេសចរណ៍ ដែលមានរាងមូលហើយមានអង្កត់ផ្ចិតប្រវែង ៦ សម និងកំពស់ ៧ សម ដែលផ្នែកខាងលើ និងខាងក្រោមមានអក្សរសម្រាប់សំគាល់មគ្គុទ្ទេសក៍ទេសចរណ៍។
- នៅលើដៃអាវខាងស្ដាំ ត្រូវមានស្លាកសញ្ញាសម្គាល់ថ្នាក់ជាតិ (រូប Cambodia Kingdom of Wonder) ដែលមានអង្កត់ផ្ចិត ៦ សម កំពស់ ៦ សម និងផ្ទៃពណ៌ស អមជាមួយរូបភាព ដែលបង្ហាញពីលក្ខណៈពិសេសសម្រាប់ថ្នាក់ជាតិ។
- ខោជើងវែងបែបសកល ពណ៌ខៀវទឹកប៊ិចចាស់ សំរាប់មគ្គុទ្ទេសក៍ទេសចរណ៍ជាបុរស ។
- ខោជើងវែងបែបសកល ឬសំពត់បត់ក្រោមជង្គង់ ពណ៌ខៀវទឹកប៊ិចចាស់ សំរាប់មគ្គុទ្ទេសក៍ទេសចរណ៍ជានារី ។
- ត្រូវមានស្បែកជើងសមរម្យ (ហាមប្រើស្បែកជើងខ្សែចំពាម ឬស្បែកជើងសង្រែក)។

## ជំពូកទី៣

## ឧទ្ទេសអាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

**ប្រការ ៣._**

អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ៖

- មានប្រវែង ៥.៥ សម និងកំពស់ ៩ សម ។
- នៅផ្នែកខាងលើ ផ្នែកខាងស្ដាំមុខអាជ្ញាបណ្ណ មានរូបថតទំហំ ៤សម គុណនឹង ៦សម។
- នៅផ្នែកខាងលើ ផ្នែកខាងឆ្វេង មានស្លាកសញ្ញាសម្គាល់របស់ក្រសួងទេសចរណ៍។
- នៅផ្នែកខាងក្រោមនៃរូបថត និងស្លាកសញ្ញាក្រសួងទេសចរណ៍មានសរសេរថា អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ (Tourism Guide License) ឈ្មោះ ភាសា ថ្ងៃខែឆ្នាំផុតសុពលភាព និងមានជាអក្សរឡាតាំងពីក្រោមនៃផ្នែកនីមួយៗ។
- នៅផ្នែកខាងក្រោម ខាងមុខអាជ្ញាបណ្ណមានហត្ថលេខា និងត្រាទទួលស្គាល់ដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍។
- ផ្នែកខាងលើ ខាងក្រោយអាជ្ញាបណ្ណមានស្លាកសញ្ញាទង់ជាតិខ្មែរ មានអង្កត់ផ្ចិត ២.៥ សម និងកំពស់ ៣.៥ សម។

- នៅផ្ទៃក្រោមខាងក្រោយអាជ្ញាបណ្ណមានលេខសម្ងាត់ពិសេស (QR Code) សម្រាប់សំគាល់មគ្គុទ្ទេសក៍ទេសចរណ៍គ្រប់រូប ដែលមានទំហំ ៣ សម ស្មើជ្រុង ដោយមានបញ្ជាក់អំពីឈ្មោះរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ហើយនិងនៅខាងក្រោមមានអក្សរដែលមានអត្ថន័យថា **មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ**។
- ខ្សែស្លាកសញ្ញាសំគាល់មគ្គុទ្ទេសក៍ទេសចរណ៍ មានទំហំ ១.៥ សម ហើយមានសរសេរជាភាសាខ្មែរ និងភាសាអង់គ្លេសនូវមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ។

អាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានចែងខាងលើជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៤

## ភារកិច្ចមគ្គុទ្ទេសក៍ទេសចរណ៍ និងទណ្ឌកម្ម

**ប្រការ ៤.**_

មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន និងស្លាកសញ្ញាសំគាល់ដែលបានកំណត់នៅពេលបំពេញការងារនាំភ្ញៀវទេសចរគ្រប់ពេលវេលា។

**ប្រការ ៥.**_

ក្នុងពេលបំពេញការងារ មគ្គុទ្ទេសក៍ទេសចរណ៍រូបណាមិនស្លៀកសំលៀកបំពាក់ឯកសណ្ឋាន និងសញ្ញាសម្គាល់ដែលបានកំណត់ខាងលើ ត្រូវទទួលពិន័យអន្តរការណ៍តាមប្រកាសលេខ ០៩៣ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ ៦.**_

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ កន្លងមកដែលមានសុពលភាពត្រូវបន្តអនុវត្តរហូតដល់អស់សុពលភាព។

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្មី ត្រូវអនុវត្តន៍តាមលក្ខខណ្ឌ និងការកំណត់ដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ ៧.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.**_

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ក្រុមអ្នកច្បាប់ គ្រប់នាយកដ្ឋាននៃក្រសួងទេសចរណ៍ ប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

*កន្លែងទទួល:*
*- ទីស្តីការគណៈរដ្ឋមន្ត្រី*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ក្រសួងមហាផ្ទៃ*
*- ក្រសួងស្ថាប័នពាក់ព័ន្ធ*
*- អគ្គស្នងការដ្ឋាននគរបាលជាតិ*
*"ដើម្បីជ្រាបជាព័ត៌មាន"*
*- សាលារាជធានី-ខេត្ត-*
*- ដូចក្នុងប្រការ ៨*
*"ដើម្បីអនុវត្ត"*
*- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍*
*- សមាគមទីភ្នាក់ងារទេសចរណ៍*
*"ដើម្បីមុខការ"*
*- ឯកសារ-កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី១
# ស្តីពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ






# ឧបសម្ព័ន្ធទី២
# ស្តីពីអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ




